# ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

# វិទ្យាស្ថាន វ៉ាន់ដា

VANDA INSTITUTE

## សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ប្រសិទ្ធភាពនៃការគ្រប់គ្រងឥណទេយ្យ
# របស់ក្រុមហ៊ុន ខ្មែរ ប៊ែវើរីជីស

EFFECTIVE OF MANAGEMENT
ACCOUNT RECEIVABLE OF KHMER BEVERAGES

## ជំនាញ គណនេយ្យ

**រាជធានីភ្នំពេញ-ឆ្នាំ២០២៤**

PHNOM PENH-2024

ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

វិទ្យាស្ថាន វ៉ាន់ដា

VANDA INSTITUTE

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ប្រសិទ្ធភាពនៃការគ្រប់គ្រងឥណទេយ្យ
# របស់ក្រុមហ៊ុន ខ្មែរ ប៊ែវើរីជីស

EFFECTIVE OF MANAGEMENT ACCOUNTRECEIVABLEOF
KHMER BEVERAGES

សាស្ត្រាចារ្យណែនាំ៖ ឆា សុថាន

ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៤

PHNOM PENH-2024

## គណៈកម្មការត្រួតពិនិត្យសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២១

## ប្រធានបទៈ ប្រសិទ្ធភាពនៃការគ្រប់គ្រងឥណទេយ្យរបស់ក្រុមហ៊ុន ខ្មែរ ប៊ែវើរីជីស

| | |
|---|---|
| គណៈកម្មការវាយតម្លៃទី១ | សាស្ត្រាចារ្យណែនាំ |
| បេក្ខបណ្ឌិត ស្រេង ផល្លា | ជា សុថាន |
| គណៈកម្មការវាយតម្លៃទី៣ | គណៈកម្មការវាយតម្លៃទី២ |
| បេក្ខបណ្ឌិត យ៉ាក វុទ្ធី | បេក្ខបណ្ឌិត មាស សំណាង |
| ប្រធានគណៈកម្មការវាយតម្លៃ និងជាប្រធានមជ្ឈមណ្ឌលស្រាវជ្រាវ | គណៈកម្មការវាយតម្លៃទី៤ |
| បណ្ឌិត សេង សំអឿន | បេក្ខបណ្ឌិត យ៉ែម សុខហៀក |
| **នាយកវិទ្យាស្ថាន** | នាយិការងអចិន្ត្រៃយ៍ |
| **បណ្ឌិត ហេង វ៉ាន់ដា** | បណ្ឌិត ហ៊ូ គុជគន្ធលីនណា |

# អារម្ភកថា

(Impression)

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញ គណនេយ្យនៅវិទ្យាស្ថាន វ៉ាន់ដា អស់រយៈពេល៤ឆ្នាំសិក្សារួចមក ក្រុមយើងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើន ពាក់ព័ន្ធនឹងមុខវិជ្ជាគណនេយ្យជាពិសេសក្រុមយើងខ្ញុំយល់ច្បាស់ថាជំនាញគណនេយ្យ គឺជាជំនាញមួយមានសារៈសំខាន់មួយដែរសម្រាប់ទីផ្សារបច្ចុប្បន្នក្នុងនោះស្ថាប័នរដ្ឋក្តី ឯកជនក្តី ឬអង្គការក្រៅរដ្ឋាភិបាលក្តី សុទ្ធតែត្រូវអនុវត្តកិច្ចការធនាគារដូចគ្នា។ ដោយឡែក ដើម្បីឱ្យការសិក្សារបស់និស្សិតកាន់តែមានគុណភាពខ្ពស់ វិទ្យាស្ថាន វ៉ាន់ដា បានបញ្ចូលនូវមុខជំនាញសំខាន់ៗដែលពាក់ព័ន្ធនឹងការងារ គណនេយ្យនិងហិរញ្ញវត្ថុនិងធនាគារ តាមកម្មវិធីសិក្សាក្នុងឆ្នាំសិក្សាទីមួយរហូតដល់ឆ្នាំសិក្សាទី៤។

គ្រប់មុខវិជ្ជាទាំងអស់ សុទ្ធតែមានសារៈសំខាន់ក្នុងការត្រួសត្រាយផ្លូវនិស្សិតឱ្យយល់ច្បាស់ពីការអនុវត្តការងារធនាគារពីការចាប់ផ្តើមរៀបចំផែនការ ការអនុវត្ត ការបញ្ចប់ និងត្រួតពិនិត្យ វាយតម្លៃព្រមទាំងផ្តល់ជាអនុសាសន៍នៅក្នុងការងារធនាគារ ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រងនៅក្នុងស្ថាប័នខ្លួន ក្នុងន័យឆ្លើយតបឱ្យបានល្អប្រសើរនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ។ ដោយក្រុមយើងខ្ញុំសង្កេតឃើញថាកិច្ចការងារមួយនេះមានសារៈសំខាន់ខ្លាំងស្របពេលនៃការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្របានមកដល់ ទើបក្រុមយើងខ្ញុំសម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយស្តីពី "**ប្រសិទ្ធភាពនៃការគ្រប់គ្រងឥណទេយ្យរបស់ក្រុមហ៊ុន ខ្មែរ ប៉ែរវីជីស**" យកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងក្នុងគោលបំណងឱ្យអ្នកស្រាវជ្រាវទាំងអស់ ឱ្យយល់កាន់តែស៊ីជម្រៅពីការរៀបចំសារណា និងប្រសិទ្ធភាពនៃការផ្តល់ឥណទានរបស់ធនាគារ។ ក្រុមយើងខ្ញុំសង្ឃឹមថាការរៀបចំសារណានេះ នឹងបានចូលរួមចំណែកក្នុងការស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗ ព្រមទាំងអ្នកស្រាវជ្រាវដ៏ទៃទៀតដែលមានបំណងសិក្សាស្វែងយល់ពីកិច្ចការនេះ។

ជាទីបញ្ចប់ក្រុមយើងខ្ញុំ សូមមេត្តាខន្តី អភ័យទោស ពីសំណាក់លោកគ្រូ អ្នកគ្រូ រៀមច្បង និងអ្នកអានទាំងអស់ នូវរាល់កំហុសឆ្គងដែលកើតមានដោយអចេតនា នៅក្នុងសារណានេះ ហើយក្រុមយើងខ្ញុំរីករាយនឹងទទួលយករាល់ការរិះគន់ក្នុងន័យស្ថាបនា ដើម្បីឱ្យការរៀបចំលើកក្រោយទៀតមានភាពកាន់តែល្អប្រសើរ។

# រចនាសម្ព័ន្ធក្រុម



ចិ សម្ផស្ស

ID: VI21/017



ជាតិ សុឌីណា

ID: VI21/010



អាន ពៅ

ID: VI21/044



មឿន ម៉េងហ័រ

ID: VI21/021

# សេចក្តីថ្លែងអំណរគុណ

ក្រុមយើងខ្ញុំ ជានិស្សិតនៃវិទ្យាស្ថាន វ៉ាន់ដា ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២១ ជំនាញ គណនេយ្យ

**សូមសំដែងនូវការគោរពដឹងគុណ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ**

ក្រុមគ្រួសារដែលបានជួយឧបត្ថម្ភ គាំទ្រ ទាំងសម្ភារៈ ថវិកា និងស្មារតី ជំរុញលើកទឹកចិត្ត ដល់ក្រុមយើងខ្ញុំ ក្នុងការសិក្សារៀនសូត្រដើម្បីទទួលបានចំណេះដឹងរហូតមកដល់សព្វថ្ងៃនេះ។ ក្នុងនោះក្រុមយើងខ្ញុំសូមសំដែងនូវការគោរព និងកត្តញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុត ដល់អ្នកមានគុណ ដែលបានផ្តល់កំណើតដល់នាងខ្ញុំគ្រប់រូប និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់បណ្ឌាសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ ទាំងអស់ដែលបានបណ្តុះបណ្តាលក្រុមយើងខ្ញុំនាពេលកន្លងមក។

ក្រុមយើងខ្ញុំ សូមសំដែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅដល់ឯកឧត្តមបណ្ឌិត **ហេង វ៉ាន់ដា** នាយកនៃវិទ្យាស្ថាន វ៉ាន់ដាដែលបានផ្តល់ទីកន្លែងបណ្តុះបណ្តាល ព្រមទាំងផ្តល់បទពិសោធន៍យ៉ាងច្រើនដល់យើងខ្ញុំ។

សូមគោរពថ្លែងអំណរគុណចំពោះសាស្ត្រាចារ្យ **ឆា សុថាន** ជាសាស្ត្រាចារ្យណែនាំ ដោយបានជួយជ្រោមជ្រែង បង្ហាត់បង្ហាញសព្វបែបយ៉ាង ដើម្បីជួយដល់ក្រុមយើងខ្ញុំបញ្ចប់កិច្ចការសារណានេះជាស្ថាពរ។ សូមគោរពថ្លែងអំណរគុណដល់សាស្ត្រាចារ្យ និងបុគ្គលិកនៃវិទ្យាស្ថានវ៉ាន់ដាទាំងអស់ដែលបានខិតខំប្រឹងប្រែងក្នុងការបង្ហាត់បង្ហាញ លើកទឹកចិត្ត អនុគ្រោះដល់ក្រុមយើងខ្ញុំ រហូតធ្វើឱ្យការសិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ឆ្លៀតក្នុងឱកាសនេះដែរ ក្រុមយើងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់បុគ្គលទាំងអស់ ខាងលើឱ្យជួបតែពុទ្ធពរបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អំណះអំណាង

ក្រុមយើងខ្ញុំ ជានិស្សិតបរិញ្ញាបត្រ ជំនាញគណនេយ្យនៃវិទ្យាស្ថាន វ៉ាន់ដា ជំនាន់ទី២១៖ សូមធានាអះអាងថា ខ្លឹមសារសារណាក្រោមប្រធានបទ "**ប្រសិទ្ធភាពនៃការគ្រប់គ្រងឥណទេយ្យរបស់ក្រុមហ៊ុន ខ្មែរ ប៊ែវើរីជីស**" នេះគឺជាស្នាដៃរបស់ក្រុមនាងខ្ញុំ ដោយគ្មានការពាក់ព័ន្ធនឹងរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ទិន្នន័យ និងលទ្ធផលនៃការស្រាវជ្រាវ ដែលលើកឡើងនេះ ជាអត្ថបទស្រាវជ្រាវថ្មីសុទ្ធសាធ ដែលពុំធ្លាប់មានជនណាម្នាក់យកទៅប្រើប្រាស់ក្នុងការស្រាវជ្រាវពីមុនឡើយ។

ថ្ងៃ. ............... ខែ.......... ឆ្នាំ..... ...... ព.ស.២៥៦....

ថ្ងៃទី.......... ខែ.......... ឆ្នាំ២០២....

**ហត្ថលេខាតំណាងក្រុម**

# សេចក្តីសង្ខេបនៃការស្រាវជ្រាវ

ក្រោយពេលបញ្ចប់ថ្នាក់បរិញ្ញាបត្រ វិទ្យាស្ថាន គឺតម្រូវឱ្យក្រុមនិស្សិតសិក្សាស្រាវជ្រាវជាអត្ថបទមួយដើម្បីបំពេញទៅតាមលក្ខខណ្ឌរបស់វិទ្យាស្ថាន ព្រមទាំងឱ្យប្អូនៗជំនាន់ក្រោយបានសិក្សាស្រាវជ្រាវ និងបន្សល់ទុកជាស្នាដៃដែលបានសិក្សាតាំងពីឆ្នាំទី១រហូតដល់ឆ្នាំទី៤កន្លងមក។

ការសិក្សាស្រាវជ្រាវមួយនេះក្រុមខ្ញុំបាទមានគោលបំណងស្វែងយល់ពីប្រវត្តិរបស់ក្រុមហ៊ុន រចនាសម្ព័ន្ធ ផលិតផល ចក្ខុវិស័យ បេសកកម្ម គោលដៅ ប្រព័ន្ធគ្រប់គ្រងបុគ្គលិក ប្រព័ន្ធគ្រប់គ្រងរបាយការណ៍ សារៈសំខាន់នៃការគ្រប់គ្រងឥណទេយ្យជាពិសេសនោះ គឺវិធីសាស្ត្រក្នុងការគ្រប់គ្រងឥណទេយ្យឱ្យមានប្រសិទ្ធភាព។ ការប្រមូលទិន្នន័យសារណាទៅលើប្រធានបទ៖ «**ប្រសិទ្ធភាពនៃការគ្រប់គ្រងឥណទេយ្យរបស់ក្រុមហ៊ុន ខ្មែរ ប៊ែវើរីជីស**» នេះក្រុមរបស់ខ្ញុំបាទបានជួបនូវរាល់បញ្ហាជាច្រើន ដើម្បីយកមកចងក្រងជាសៀវភៅ ដោយស្រាវជ្រាវដំបូង គឺសិក្សាពីទ្រឹស្តីសិនរហូតបានក្រុមរបស់ខ្ញុំបាទបានយល់កាន់តែច្បាស់ពីការងារអនុវត្តជាក់ស្តែងដែលដូចនូវទ្រឹស្តីដែលធ្លាប់បានសិក្សា។

ការគ្រប់គ្រងគណនីឥណទេយ្យ គឺជាដំណើរការត្រួតពិនិត្យ និងគ្រប់គ្រងប្រាក់ដែលអតិថិជនជំពាក់ក្រុមហ៊ុនសម្រាប់ទំនិញ ឬសេវាកម្មដែលបានទិញដោយឥណទាន។ ការគ្រប់គ្រងគណនីទទួល មានគោលនយោបាយ និងនីតិវិធីដែលបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងគណនី និងកាត់បន្ថយហានិភ័យ នៃបំណុលអាក្រក់។ ការគ្រប់គ្រងគណនីទទួល ធានាថាក្រុមហ៊ុនទទួលបានការទូទាត់ទាន់ពេលវេលាតាមការកំណត់ និងមិនមានភាពយឺតយ៉ាវ។ គោលនយោបាយគ្រប់គ្រងគណនីល្អអាចបង្កើនលំហូរសាច់ប្រាក់ កែលម្អដំណើរការប្រមូលប្រាក់ និងធ្វើឱ្យក្រុមហ៊ុនរបស់អ្នកបង់ប្រាក់កាន់តែលឿន ហើយក៏អាចបង្កើនបទពិសោធន៍របស់អតិថិជនបានយ៉ាងច្រើនផងដែរ។ ដូចគ្នានេះដែរ ការអនុវត្តមិនល្អអាចវានឹងរារាំងដល់ការលូតលាស់របស់ស្ថាប័ន ក្នុងការអនុវត្តនេះយើងត្រូវកំណត់លក្ខខណ្ឌឥណទាន និងដែនកំណត់ តាមដានភាពសក្តិសមនៃឥណទាន តាមដានវិក័យបត្រអតិថិជន តាមដានការបង់ប្រាក់យឺត ការប្រមូលគណនីហួសកាលកំណត់។

ជាការពិតណាស់កាលណាបើយើងបានសិក្សាទៅលើវិធីសាស្ត្រការគ្រប់គ្រងឥណទេយ្យបានល្អនោះវាពិតជាចំណែកមួយដែលធ្វើឱ្យក្រុមហ៊ុនមានការរីចចម្រើនទៅមុខបន្តយ៉ាងរលូន។

តាមរយៈការសិក្សាស្រាវជ្រាវរួចមកក្រុមខ្ញុំបាទអាចសន្និដ្ឋានបានថាក្រុមហ៊ុន ខ្មែរ ប៊ែវើរីជីស គឺជាក្រុមហ៊ុនមួយដែលមានភាពល្បីល្បាញ លេចធ្លោជាងគេក្នុងការផលិត ផលិតផលមានអនាម័យល្អ ការដឹកនាំ និងការគ្រប់គ្រងប្រកបទៅដោយប្រសិទ្ធភាពខ្ពស់ មិនត្រឹមតែលេចធ្លោនៅក្នុងប្រទេសកម្ពុជាទេ ឈានដល់ក្រៅប្រទេសមួយចំនួនទៀតផង។ ប៉ុន្តែទោះជាយ៉ាងណាក្រុមហ៊ុនក៏នៅតែមានចំណុចខ្វះខាតផងដែរ។ ហេតុដូចនេះហើយទើបក្រុមខ្ញុំបាទ សូមធ្វើការផ្តល់ជាអនុសាសន៍ទៅលើក្រុមហ៊ុន គួរតែកាត់បន្ថយទៅលើចំណាយផ្សេងៗដែលមិនសូវជាចាំបាច់ច្រើនហួសពេក វាបណ្តាលឱ្យបាត់បង់នូវចំណូលច្រើន។

# មាតិកា

ទំព័រ

អារម្ភកថា ..... i

រចនាសម្ព័ន្ធ ..... ii

សេចក្តីថ្លែងអំណរគុណ ..... iii

អំណះអំណាង ..... iv

សេចក្តីសង្ខេបនៃការស្រាវជ្រាវ ..... v

## ជំពូកទី១
## សេចក្តីផ្តើម

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ..... ១

១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ..... ១

**១.តើការគ្រប់គ្រងឥណទេយ្យមានសារៈសំខាន់អ្វីខ្លះសម្រាប់ក្រុមហ៊ុន ខ្មែរ ប៉ែវើរីជីស?**

**២.តើក្រុមហ៊ុន ខ្មែរ ប៉ែវើរីជីសមានវិធីសាស្ត្រដូចម្តេច ក្នុងការគ្រប់គ្រងឥណទេយ្យឱ្យមានប្រសិទ្ធភាព?**

១.៣ គោលបំណងនៃការស្រាវជ្រាវ ..... ២

១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ..... ២

១.៤.១ ទំហំដែនកំណត់ ..... ២

១.៤.២ វិសាលភាពនៃការស្រាវជ្រាវ ..... ២

១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ ..... ៣

១.៥.១ ការប្រមូលទិន្នន័យដំបូង ..... ៣

១.៥.២ ការប្រមូលទិន្នន័យបន្ទាប់ ..... ៣

១.៦ សារៈសំខាន់នៃការស្រាវជ្រាវ ..... ៣

១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ..... ៤

## ជំពូកទី២
## ប្រសិទ្ធភាពនៃការគ្រប់គ្រងឥណទេយ្យរបស់ក្រុមហ៊ុន

២.១ លក្ខណៈទូទៅនៃការគ្រប់គ្រងឥណទេយ្យរបស់ក្រុមហ៊ុន ..... ៥

២.១.១ និយមន័យ ..... ៥

២.១.២ ប្រវត្តិនៃការកើតឡើងឥណទេយ្យ ..... ៦

២.១.៣ ទ្រឹស្តីទាក់ទងការគ្រប់គ្រងឥណទេយ្យ ..... ៧

២.២ សារៈសំខាន់ក្នុងការគ្រប់គ្រងឥណទេយ្យរបស់ក្រុមហ៊ុន ..... ៩

២.២.១ និយមន័យ ..... ៩

២.២.២ មុខងារនៃការគ្រប់គ្រង ..... ១០

២.២.៣ ទ្រឹស្តីនៃសារៈសំខាន់ក្នុងការគ្រប់គ្រងឥណទេយ្យ ..... ១០

២.៣ វិធីសាស្ត្រក្នុងការគ្រប់គ្រងឥណទេយ្យរបស់ក្រុមហ៊ុនឱ្យមានប្រសិទ្ធភាព ......................................... ១១
២.៣.១ និយមន័យ ........................................................................................................ ១១
២.៣.២ ប្រវត្តិនៃវិធីសាស្ត្រ ............................................................................................... ១១
២.៣.៣ ទ្រឹស្តីដែលពាក់ព័ន្ធវិធីសាស្ត្រ ..................................................................................... ១២

## ជំពូកទី៣
## ប្រសិទ្ធភាពនៃការគ្រប់គ្រងឥណទេយ្យរបស់
## ក្រុមហ៊ុន ខ្មែរ ប៊ែវើរីជីស

៣.១ ស្ថានភាពទូទៅនៃក្រុមហ៊ុន ខ្មែរ ប៊ែវើរីជីស ........................................................................ ១៤
៣.១.១ ប្រវត្តិរបស់ក្រុមហ៊ុន ខ្មែរ ប៊ែវើរីជីស ប៊ែវើរីជីស ..................................................... ១៤
៣.១.២ សញ្ញាសម្គាល់របស់ក្រុមហ៊ុន ខ្មែរ ............................................................................ ១៥
៣.១.៣ ទីតាំងរបស់ក្រុមហ៊ុន ខ្មែរ ប៊ែវើរីជីស ........................................................................ ១៥
៣.១.៤ ផលិតផលរបស់ក្រុមហ៊ុន ខ្មែរ ប៊ែវើរីជីស ..................................................................... ១៥
ក.ស្រាបៀរ កម្ពុជា( Cambodia Beer) ................................................................... ១៦
ខ.ភេសជ្ជៈប៉ូវកម្លាំង វើក ( WURKZ) ..................................................................... ១៧
គ.ទឹកក្រូច អាយស៍( IZE) .......................................................................................... ១៨
ឃ.ទឹកបរិសុទ្ធ កម្ពុជា ( Cambodia Water) ............................................................ ១៩
ង.ភេសជ្ជៈប៉ូវកម្លាំង អាយស៊ី យូល ( Cambodia ICV COOL) ................................... ១៩
ច.ភេសជ្ជៈអិចប្រេស (Exprez Cambodia) ............................................................. ២០
ឆ.ភេសជ្ជៈប៉ូវកម្លាំង ឃីស ( KIZZ ) ........................................................................ ២០
៣.១.៥ ចក្ខុវិស័យ បេសកកម្ម គោលដៅ របស់ក្រុមហ៊ុន ខ្មែរ ប៊ែវើរីជីស .............................. ២១
ក.ចក្ខុវិស័យ ............................................................................................................ ២១
ខ.បេសកកម្ម ............................................................................................................ ២១
គ.គោលតម្លៃ ............................................................................................................ ២១
៣.១.៦ រចនាសម្ព័ន្ធគ្រប់គ្រង តួនាទី នឹងភារកិច្ច របស់ក្រុមហ៊ុន ខ្មែរ ប៊ែវើរីជីស ..................... ២២
ក. រចនាសម្ព័ន្ធគ្រប់គ្រង ............................................................................................ ២២
ខ. តួនាទី និងភារកិច្ចរបស់គណៈគ្រប់គ្រង .................................................................. ២៣
៣.២ សារៈសំខាន់ក្នុងការគ្រប់គ្រងឥណទេយ្យរបស់ក្រុមហ៊ុន ខ្មែរ ប៊ែវើរីជីស ........................................ ២៣
៣.២.១ បង្កើតមូលដ្ឋានគ្រឹះនៃការគ្រប់គ្រងឥណទេយ្យ ......................................................... ២៣
៣.២.២ បង្កើនឱកាសក្នុងការលក់ ........................................................................................ ២៤
៣.២.៣ បង្កើនទំនាក់ទំនងជាមួយអតិថិជន ............................................................................ ២៥
៣.២.៤ បង្កើតការកែលម្អការគ្រប់គ្រងគណនីឥណទេយ្យ ........................................................ ២៦
ក.បង្កើតលក្ខខណ្ឌបង់ប្រាក់ ......................................................................................... ២៤
ខ.ត្រួតពិនិត្យវិក្កយបត្រ ............................................................................................ ២៤

គ.អនុវត្តគោលការណ៍បង់ប្រាក់ ............ ២៤
ឃ.ដោះស្រាយវិវាទការទូទាត់ឱ្យបានទាន់ពេលវេលា ............ ២៤
ង.ផ្ដល់ជូនជម្រើសបង់ប្រាក់ ............ ២៥
៣.២.៥ បង្កើនការគ្រប់គ្រងលើមូលធន ............ ២៥
៣.២.៦ កាត់បន្ថយហានិភ័យឥណទាន ............ ២៥
៣.៣ វិធីសាស្ត្រក្នុងការគ្រប់គ្រងឥណទេយ្យឱ្យមានប្រសិទ្ធភាពរបស់ក្រុមហ៊ុន ខ្មែរ ប៉ែវើរីជីស ............ ២៥
៣.៣.១ កំណត់ផែនការយុទ្ធសាស្ត្រ ............ ២៦
៣.៣.២ កំណត់ប្រព័ន្ធសំខាន់ៗក្នុងការគ្រប់គ្រងគណនីឥណទេយ្យ ............ ២៦
៣.៣.៣ គ្រប់គ្រងដំណើរការគណនីអតិថិជន ............ ២៧
៣.៣.៤ គ្រប់គ្រងនៃការប្រមូលសាច់ប្រាក់ ............ ៣០
៣.៣.៥ បង្កើនល្បឿនការប្រមូលសាច់ប្រាក់ ............ ៣០

## ជំពូកទី៤
## ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

៤.១ ការវិភាគលើចំណុចខ្លាំង ............ ៣១
៤.២ ការវិភាគលើចំណុចខ្សោយ ............ ៣១

## ជំពូកទី៥
## សេចក្ដីសន្និដ្ឋាន និងការផ្ដល់អនុសាសន៍

៥.១ សេចក្ដីសន្និដ្ឋាន ............ ៣៣
៥.២ ការផ្ដល់អនុសាសន៍ ............ ៣៣
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# ជំពូកទី១
# សេចក្តីផ្តើម

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

នាសម័យបច្ចុប្បន្ននេះ នៅក្នុងប្រទេសកម្ពុជាគឺមានការអភិវឌ្ឍគ្រប់វិស័យ មិនថាវិស័យសេវាកម្ម ផលិតកម្ម ឧស្សាហកម្ម ជាពិសេសនោះគឺវិស័យពាណិជ្ជកម្ម។ នៅក្នុងពិភពលោកទាំងមូលមានការចាប់បើកចំហរនូវសេដ្ឋកិច្ចទីផ្សារ និងការទំនាក់ទំនងពាណិជ្ជកម្មយ៉ាងល្អខ្ជាប់ខ្ជួនជាមួយបណ្តាប្រទេសនានានៅលើពិភពលោក។ កត្តាទាំងនេះបានជម្រុញការលើកទឹកចិត្តយ៉ាងខ្លាំងដល់ប្រជាពលរដ្ឋ និងអ្នកវិនិយោគស្រប ពេលដែលសេដ្ឋកិច្ចទីផ្សារលើពិភពលោកកំពុងតែមានការរីកចម្រើនលើគ្រប់វិស័យ ជាពិសេសទៅលើវិស័យពាណិជ្ជកម្ម មានការកើនឡើងជារៀងរាល់ថ្ងៃ។ យើងសង្កេតឃើញថាសព្វថ្ងៃនេះ លំហូរនៃអ្នកវិនិយោគទុនក្នុង និងក្រៅប្រទេសគឺបានចូលរួមបណ្តាក់ទុនវិនិយោគទៅលើវិស័យពាណិជ្ជកម្មជាច្រើននៅក្នុងប្រទេស ដែលធ្វើឱ្យប្រទេសកម្ពុជាកាន់តែមានភាពរីកចម្រើនគួរឱ្យសម្គាល់។ ដោយសារមានការកើនឡើងជាច្រើននេះហើយ ដែលធ្វើឱ្យក្រុមហ៊ុនពាណិជ្ជកម្មខ្លះទទួលបានជោគជ័យ និងខ្លះទៀតមានហានិភ័យខ្ពស់ទៅលើកាគ្រប់គ្រងផងដែរ។ នៅក្នុងប្រទេសកម្ពុជាប្រភពដែលធ្វើឱ្យសេដ្ឋកិច្ចរីកចម្រើនគឺតាមរយៈការធ្វើអាជីវកម្មរបស់ក្រុមហ៊ុនពាណិជ្ជកម្ម។ យើងសង្កេតឃើញថាសព្វថ្ងៃនេះ មានអ្នកវិនិយោគកំពុងធ្វើការវិនិយោគ និងការបណ្តាក់ទុនប្រកួតប្រជែងគ្នានៅក្នុងប្រទេសកម្ពុជាយើងជាច្រើន។

ជាក់ស្តែងក្រុមហ៊ុនខ្មែរ ប៊ែវើរីជីស ជាក្រុមហ៊ុនមួយដែលមានការគ្រប់គ្រងបានល្អជាងគេ ដោយផ្តោតទៅលើការផលិតស្រាបៀរ ដែលមានគុណភាពខ្ពស់ ព្រមទាំងការផលិតភេសជ្ជៈផ្សេងៗទៀតនាំមុខគេនៅប្រទេសកម្ពុជា ដែលកាន់កាប់ភាគហ៊ុន ១០០ភាគរយ ដោយវិនិយោគិនកម្ពុជា។ បន្ថែមពីនេះទៅទៀត ក្រុមហ៊ុនខ្មែរ ប៊ែវើរីជីស បានបំពេញតួនាទីរបស់ខ្លួនយ៉ាងសំខាន់ក្នុងការដោះស្រាយបញ្ហាសង្គមតាមរយៈការបង្កើតបានជាក្រុមហ៊ុនដែលមានស្តង់ដា និងគុណភាពដោយឆ្លងកាត់តាមខ្សែរសង្វាក់ផលិតកម្មយ៉ាងត្រឹមត្រូវក្នុងការចូលរួមស្វែងរកទីផ្សារដើម្បីសម្រេចបានភាពជោគជ័យនៃការគ្រប់គ្រង ក៏ដូចជាការផ្តល់ឱកាសការងារដល់ប្រជាជន ដើម្បីជួយឱ្យប្រជាជនមានចំណូល ងាយស្រួលក្នុងការបែងចែកធនធានសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ កាត់បន្ថយភាពក្រីក្ររបស់ប្រជាជន កាត់បន្ថយភាពគ្មានការងារធ្វើរបស់ប្រជាជន។

ចំណុចចាប់ផ្តើមនៃអាជីវកម្ម ត្រូវតែស៊ីចង្វាក់ជាមួយគោលដៅ ខ្សែរសង្វាក់ផលិតកម្មដំណើរការ ផលិត ការស្វែងរកទីផ្សារ ការស្វែងរកទីកន្លែងសម្រាប់លក់ ឬការផ្សព្វផ្សាយពាណិកម្មជូនអតិថិជនជាដើម។ ចំណុចចាប់ផ្តើម ត្រូវតែមានការចូលរួមមតិគ្នាចេញជាចំណុចតូចៗ ឬជាជំហានឆ្ពោះទៅកាន់គោលដៅ ភាពជោគជ័យដើម្បីងាយស្រួលក្នុងការគ្រប់គ្រងក្រុមហ៊ុន។ ដូច្នេះហើយទើបក្រុមខ្ញុំបាទ សម្រេចជ្រើសរើសយកប្រធានបទ **ប្រសិទ្ធភាពនៃការគ្រប់គ្រងឥណទេយ្យរបស់ក្រុមហ៊ុនខ្មែរ ប៊ែវើរីជីស** យកមកធ្វើជាការស្រាវជ្រាវ និងចងក្រងជាឯកសារសម្រាប់ទុកឱ្យនិស្សិតជំនាន់ក្រោយយកមកសិក្សាបន្ត។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

នៅក្នុងប្រទេសកម្ពុជាសព្វថ្ងៃនេះ គឺមានការប្រកួតប្រជែងយ៉ាងខ្លាំងទៅលើគ្រប់វិស័យ ដោយសារតែមានការប្រកួតប្រជែងច្រើននេះហើយ ទើបក្រុមហ៊ុននីមួយៗតែងតែមានវិធីសាស្ត្រគ្រប់គ្រងរបាយការណ៍ហិរញ្ញវត្ថុ

មានលក្ខណៈពិសេសផ្សេងៗគ្នាទៅតាមក្រុមហ៊ុន ឬអង្គភាព ទោះជាយ៉ាងណាក្រុមហ៊ុនខ្មែរ ប៊ែរវើរីជីស គឺជាក្រុមហ៊ុនមួយដែលកំពុងតែឈានមុខគេព្រមទាំងមានការគាំទ្រពីសំណាក់អតិថិជន ហើយមានការទទួលស្គាល់ពីក្រសួងសុខាភិបាលកម្ពុជា និងវិទ្យាស្ថានវាយតម្លៃគុណភាពអន្តរជាតិ( Monde Selection International Quality) ដែលមាននៅក្នុងប្រទេសកម្ពុជា។ ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍទៅលើការគ្រប់គ្រងប្រព័ន្ធឥណទេយ្យរបស់ក្រុមហ៊ុនឱ្យមានប្រសិទ្ធភាព ក្រុមយើងខ្ញុំសូមលើកនូវសំណួរមួយចំនួនដើម្បីទុកជាទស្សនៈវិស័យ និងជាផែនទីបង្ហាញផ្លូវក្នុងការសិក្សាស្រាវជ្រាវដូចតទៅ៖

១.តើការគ្រប់គ្រងឥណទេយ្យមានសារៈសំខាន់អ្វីខ្លះ សម្រាប់ក្រុមហ៊ុន ខ្មែរ ប៊ែរវើរីជីស?

២.តើក្រុមហ៊ុន ខ្មែរ ប៊ែរវើរីជីសមានវិធីសាស្ត្រដូចម្តេច ក្នុងការគ្រប់គ្រងឥណទេយ្យឱ្យមានប្រសិទ្ធភាព?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ក្នុងស្នាដៃមួយនេះត្រូវបានធ្វើឡើងដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់អំពីវិធីសាស្ត្រគ្រប់គ្រងឥណទេយ្យដើម្បីឱ្យដឹងកាន់តែស៊ីជម្រៅចំពោះលក្ខណៈពិសេសៗដោយឡែករបស់ក្រុមហ៊ុន និងពិនិត្យផ្តោតសំខាន់ទៅលើប្រសិទ្ធភាពការគ្រប់គ្រងឥណទេយ្យរបស់ក្រុមហ៊ុន ហេតុនេះហើយយើងត្រូវស្វែងយល់ពីចំណុចសំខាន់ៗដូចខាងក្រោម៖

- ស្ថានភាពទូទៅរបស់ក្រុមហ៊ុន ខ្មែរ ប៊ែរវើរីជីស
- ផ្តោតទៅលើរចនាសម្ព័ន្ធចាត់តាំងរបស់ក្រុមហ៊ុន
- ផ្នែកឥណទេយ្យ
  - ការគ្រប់គ្រងទៅលើប្រព័ន្ធឥណទេយ្យរបស់ក្រុមហ៊ុន ខ្មែរ ប៊ែរវើរីជីស
  - ការផ្តល់សេវាទៅឱ្យអតិថិជន
  - ការប្រមូលឥណទេយ្យ
  - នីតិវិធី និងដំណោះស្រាយឥណទេយ្យពេលមានបញ្ហា
  - ផ្សព្វផ្សាយប្រព័ន្ធឥណទេយ្យ
  - ស្វែងរកចំណុចខ្លាំង និងចំណុចខ្សោយ។

## ១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ដើម្បីសិក្សាស្រាវជ្រាវអំពីប្រធានបទនេះឱ្យកាន់តែស៊ីជម្រៅ មានភាពច្បាស់លាស់ និងងាយស្រួលថែមទៀត យើងបានកំណត់អំពីទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវឱ្យបានជាក់លាក់ជាមុនសិន។

### ១.៤.១ ទំហំដែនកំណត់

ក្នុងការស្រាវជ្រាវនេះក្រុមខ្ញុំបាទ បានជ្រើសរើសក្រុមហ៊ុន ខ្មែរ ប៊ែរវើរីជីស ដែលមានអាសយដ្ឋានផ្លូវ២១៧ ភូមិជើងឯក សង្កាត់ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញមកសិក្សា។

### ១.៤.២ វិសាលភាពនៃការស្រាវជ្រាវ

សម្រាប់វិសាលភាពក្នុងការសិក្សាស្រាវជ្រាវនេះ ក្រុមខ្ញុំបាទបានកំណត់យកប្រព័ន្ធគ្រប់គ្រងគណនីឥណទេយ្យ នៅក្នុងឆ្នាំ២០២២-២០២៣សម្រាប់ធ្វើការសិក្សាស្រាវជ្រាវ និងរៀបចំចងក្រងជាសៀវភៅ។

## ១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះ ក្រុមខ្ញុំបាទបានជ្រើសរើសយកវិធីសាស្ត្រស្រាវជ្រាវបែបពិពណ៌នាមកប្រើប្រាស់ ដោយសារប្រធានខាងលើនេះទាមទារការបកស្រាយឱ្យបានលម្អិត និងក្បោះក្បាយ។

### ១.៥.១ ការប្រមូលទិន្នន័យដំបូង

ការប្រមូលទិន្នន័យដំបូង គឺទទួលបានការណែនាំពីសាស្ត្រាចារ្យដឹកនាំ និងធ្វើការសាកសួរផ្ទាល់ ទៅកាន់បុគ្គលិកដែលកំពុងបម្រើការងារនៅក្នុងក្រុមហ៊ុនខ្មែរ ប៊ែវើរីជីស។

### ១.៥.២ ការប្រមូលទិន្នន័យបន្ទាប់

ការប្រមូលទិន្នន័យបន្ទាប់ គឺបានមកពីការស្រាវជ្រាវពីក្នុងបណ្ណាល័យនានា និងគេហទំព័រក្នុងប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ។

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ធ្វើឡើងក្នុងគោលបំណងផ្តោតទៅលើផលប្រយោជន៍រួមនៅក្នុងការផ្តល់ចំណេះដឹងជាជំនួយក្នុងការវិភាគជាឯកសារផ្សេងៗ ជាគន្លឹះកាន់តែល្អប្រសើរក្នុងការស្រាវជ្រាវ និងគោលបំណងផ្សេងៗទៀតដែលអាចយកប្រើប្រាស់បានសម្រាប់អ្នកអាន ជាពិសេសសម្រាប់និស្សិតជំនាន់ក្រោយដែលសិក្សាស្រាវជ្រាវ និងចង់យល់ដឹងអំពីប្រធានបទ ប្រសិទ្ធក្នុងការគ្រប់គ្រងឥណទេយ្យរបស់ក្រុមហ៊ុន ខ្មែរ ប៊ែវើរីជីស។ ការសិក្សាស្រាវជ្រាវនេះបានផ្តល់ផលប្រយោជន៍ និងចំណេះដឹងដូចជា៖

- ចំពោះខ្លួនឯង៖ យល់ដឹងពីវិធីសាស្ត្រក្នុងការគ្រប់គ្រងឥណទេយ្យជាក់ស្តែង ព្រមទាំងការលើកឡើងពីរចនាសម្ព័ន្ធនៃការគ្រប់គ្រងរបស់ក្រុមហ៊ុន ស្គាល់ពីរបៀបនៃការធ្វើសំវិធានធន ការបង្កើតនូវកម្មវិធីគ្រប់គ្រងគណនីឥណទេយ្យ ដឹងពីការវាយតម្លៃ ការបង្កើតរយៈពេលឥណទានដើម្បីបញ្ចុះភាគរយការពិន័យក្នុងករណីដែលមានការបង់ប្រាក់យឺតយ៉ាវ ហើយព្រមទាំងទទួលបាននូវចំណេះដឹង និងបទពិសោធន៍ថ្មីៗបន្ថែមទៀតពីកិច្ចកាស្រាវជ្រាវមួយនេះផងដែរ។
- ចំពោះនិស្សិតជំនាន់ក្រោយ៖ ជាឯកសារសម្រាប់ជំនួយដល់ការសិក្សាស្រាវជ្រាវ ហើយក៏អាចជាសៀវភៅក្នុងការបង្កើនចំណេះដឹងទៅលើប្រព័ន្ធឥណទេយ្យ។
- ចំពោះសាធារណជន និងប្រយោជន៍រួម៖ ជាឯកសារមួយសម្រាប់បង្វែរចំណាប់អារម្មណ៍មហាជនឱ្យមកចាប់អារម្មណ៍លើការវិនិយោគមូលបត្រកម្មសិទ្ធិ ឬភាគហ៊ុន ព្រមទាំងជាឯកសារវិភាគលើឥណទេយ្យរបស់ក្រុមហ៊ុន ខ្មែរ ប៊ែវើរីជីស។ ម្យ៉ាងវិញទៀតវាអាចធ្វើឱ្យមហាជនទទួលបានទំនុកចិត្តបន្ថែមទៀត។
- ចំពោះក្រុមហ៊ុន ខ្មែរ ប៊ែវើរីជីស៖ ទទួលបានការផ្សព្វផ្សាយពីក្រុមហ៊ុនយ៉ាងទូលំទូលាយបន្ថែមធ្វើឱ្យមហាជនស្គាល់កាន់តែច្បាស់ពីលក្ខណៈនៃការសងប្រាក់ព្រមទាំងធ្វើឱ្យអតិថិជនមានទំនុកចិត្តខ្ពស់លើក្រុមហ៊ុន ពិសេសជាងនេះទៅទៀតគឺឱ្យធ្វើក្រុមហ៊ុនមើលឃើញពីចំណុចល្អ និងចំណុចខ្វះខាតខ្លះៗ ដែលត្រូវកែលម្អឬបង្កើតថ្មីឡើងវិញ។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងការធ្វើរចនាសម្ព័ន្ធនៃការស្រាវជ្រាវ គឺមានគោលបំណងចង់បកស្រាយឱ្យបានកាន់តែច្បាស់ពីចំណុចនីមួយៗ។ ការស្រាវជ្រាវនេះត្រូវបានបែងចែកជាប្រាំផ្នែកដែលមានដូចជា សេចក្តីផ្តើម រំលឹកទ្រឹស្តី លទ្ធផលនៃការស្រាវជ្រាវ ការវិភាគចំណុចខ្លាំង និងចំណុចខ្សោយ សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍។

**ជំពូកទី១** (សេចក្តីផ្តើម)៖ លើកឡើងពីលំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណង ទំហំ និងដែនកំណត់ វិធីសាស្រ្តនៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

**ជំពូកទី២** (រំលឹកទ្រឹស្តី)៖ ចង្អុលបង្ហាញ និងលើកឡើងនូវនិយមន័យ ប្រវត្តិផ្សេងៗ ទ្រឹស្តីរបស់អ្នកប្រាជ្ញដែលពាក់ព័ន្ធជាមួយប្រធានបទនៃការគ្រប់គ្រងប្រព័ន្ធឥណទេយ្យ។

**ជំពូកទី៣** (លទ្ធផលនៃការស្រាវជ្រាវ)៖ លទ្ធផលនៃការស្រាវជ្រាវគឺបានផ្តល់ឱ្យដឹងពីស្ថានភាពជាក់ស្តែងរបស់ក្រុមហ៊ុន ទីតាំងរបស់ក្រុមហ៊ុន គោលនយោបាយ ប្រព័ន្ធនៃការគ្រប់គ្រងឥណទេយ្យ។

**ជំពូកទី៤** (ការវិភាគចំណុចខ្លាំង និងចំណុចខ្សោយ)៖ លើកឡើងពីចំណុចខ្លាំង និងចំណុចខ្សោយនៃការគ្រប់គ្រងរបស់ក្រុមហ៊ុន និងប្រព័ន្ធឥណទេយ្យ។

**ជំពូកទី៥** (សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍)៖ ការធ្វើសេចក្តីសន្និដ្ឋានលើគ្រប់ចំណុចទាំងចំណុចខ្លាំង និងចំណុចខ្សោយ ព្រមទាំងភាពខ្វះខាតទាំងឡាយ ក្នុងការផ្តល់ជាមតិ និងអនុសាសន៍ដើម្បីកែលំអឱ្យប្រសើរឡើង។

# ជំពូកទី២
# រំលឹកទ្រឹស្តី

# ជំពូកទី២

# ប្រសិទ្ធភាពនៃការគ្រប់គ្រងឥណទេយ្យរបស់ក្រុមហ៊ុន

ពីមួយថ្ងៃទៅមួយថ្ងៃ គ្រប់បណ្តាលប្រទេសបច្ចេកវិទ្យាមានការរីកចម្រើនឥតឈប់ឈរជាកត្តាដែលធ្វើឱ្យក្រុមហ៊ុនកាន់តែកើនច្រើនឡើងៗ ការគ្រប់គ្រងឥណទេយ្យ ក៏ជាចំណែកមួយដែលមានសារៈសំខាន់ណាស់សម្រាប់ក្រុមហ៊ុនទាំងអស់ ក្នុងការរក្សានូវសាច់ប្រាក់ចំណូល និងចំណាយរបស់ខ្លួន ព្រមទាំងជានាការទុក្ខចិត្តភាពត្រឹមត្រូវទៅលើរបាយការណ៍ហិរញ្ញវត្ថុ។ កាលណាមានការគ្រប់គ្រងឥណទេយ្យបានល្អនោះនឹងធ្វើឱ្យក្រុមហ៊ុន ទទួលបានភាពច្បាស់លាស់ទៅលើរបាយការណ៍ មានទំនុកចិត្ត ដឹងពីការជំពាក់ ឬមានការសងប្រាក់របស់អតិថិជន ជាពិសេសនោះគឺធ្វើឱ្យអ្នកគ្រប់គ្រងងាយស្រួលក្នុងការគ្រប់គ្រងក្រុមហ៊ុន។

## ២.១ លក្ខណៈទូទៅនៃការគ្រប់គ្រងឥណទេយ្យរបស់ក្រុមហ៊ុន

### ២.១.១ និយមន័យ

**គណនីឥណទេយ្យ** គឺជាគណនីមួយដែលបង្ហាញថាអតិថិជនជំពាក់ប្រាក់ក្រុមហ៊ុន។ គណនីឥណទេយ្យកើតឡើងដោយសារការលក់ទំនិញជឿ ឬការផ្តល់សេវាកម្មដោយជំពាក់ទៅកាន់អតិថិជន[1]។

**គណនីឥណទេយ្យ** គឺជាសមតុល្យនៃប្រាក់ដោយសារតែក្រុមហ៊ុនសម្រាប់ទំនិញ ឬសេវាកម្មដែលបានចែកចាយឬប្រើប្រាស់ប៉ុន្តែមិនទាន់បានទូទាត់ដោយអតិថិជន។ គណនីឥណទេយ្យត្រូវបានរាយក្នុងតារាងតុល្យការជាទ្រព្យសកម្មបច្ចុប្បន្ន។ ចំនួនទឹកប្រាក់ដែលអតិថិជនជំពាក់សម្រាប់ការទិញដែលបានធ្វើឡើងដោយឥណទានគឺគណនីឥណទេយ្យ[2]។

**គណនីឥណទេយ្យ** កើតឡើងដោយសារការលក់ទំនិញជឿ ឬការផ្តល់សេវាកម្មដោយជំពាក់ទៅកាន់អតិថិជន[3]។

**គណនីឥណទេយ្យ** គឺសំដៅលើប្រាក់ដែលអតិថិជនរបស់ក្រុមហ៊ុនជំពាក់សម្រាប់ទំនិញ ឬសេវាកម្មដែលពួកគេបានទទួល ប៉ុន្តែមិនទាន់បានបង់។ ឧទាហរណ៍ នៅពេលអតិថិជនទិញផលិតផលដោយឥណទានចំនួនទឹកប្រាក់ដែលជំពាក់នឹងបញ្ចូលទៅក្នុងគណនីដែលទទួល។ វាជាកាតព្វកិច្ចដែលបានបង្កើតឡើងតាមរយៈប្រតិបត្តិការអាជីវកម្ម[4]។

**គណនីឥណទេយ្យ** សំដៅលើវិក្កយបត្រដែលក្រុមហ៊ុនមាន ឬប្រាក់ដែលអតិថិជនជំពាក់ក្រុមហ៊ុន[5]។

**គណនីឥណទេយ្យ** គឺជាពាក្យគណនេយ្យដែលសំដៅលើប្រាក់ជំពាក់ក្រុមហ៊ុនដោយអតិថិជនរបស់ខ្លួន។ វាគឺជាផ្នែកមួយដ៏សំខាន់នៃរបាយការណ៍អំពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនចាប់តាំងពីវាបង្ហាញពីចំនួនប្រាក់ដែលត្រូវបានព្យាករថានឹងទទួលបានពីអតិថិជននាពេលអនាគត[6]។

---

[1] *https://www.khsearch.com/qna/24676*
[2] *https://www.techtarget.com/searcherp/definition/Accounts-receivable-AR*
[3] *https://cambodiafinancialtimes.com/archives/3729#*
[4] *https://www.bdc.ca/en/articles-tools/entrepreneurn*
[5] *https://www.bing.com/search? 1*
[6] *https://www.rsisinternational.*

**២.១.២ ប្រវត្តិនៃការកើតឡើងឥណទេយ្យ**

គណនីដែលត្រូវទទួល គឺជាជម្រើសសម្រាប់អាជីវកម្មក្នុងការទិញ និងបង្កើនលំហូរសាច់ប្រាក់បានយូរជាងវាថែមទាំងមានឈ្មោះទៀតផង។ ជាការពិតណាស់ វិធីសាស្ត្របានផ្លាស់ប្តូរ និងកែលម្អពេញមួយប្រវត្តិសាស្ត្រ ប៉ុន្តែវាជាជម្រើសយូរមកហើយសម្រាប់ក្រុមហ៊ុនមួយក្នុងការទិញទំនិញ និងបង់ប្រាក់សម្រាប់ពួកគេដោយបត់បែននៅពេលក្រោយ។ យើងនឹងក្រឡេកមើលប្រវត្តិសាស្ត្រឡើងវិញនៅទីកន្លែង និងពេលណាដែលគណនីទទួលត្រូវបានបង្កើតឡើង និងរបៀបដែលវាបានវិវត្តទៅជាអ្វីដែលយើងដឹងដូចសព្វថ្ងៃនេះ។

**2000 មុន គ.ស៖** ស្ថាបនិកនៃគណនីទទួលជនជាតិ Mesopotamians បានបង្កើតទម្រង់នៃកត្តាស្រដៀងគ្នាទៅនឹងអ្វីដែលយើងប្រើសព្វថ្ងៃនេះ ដោយអនុញ្ញាតឱ្យអាជីវកម្មទិញទំនិញ និងទូទាត់ប្រាក់នៅពេលក្រោយ។ ច្បាប់ផ្លូវការដំបូងនៃគណនីដែលទទួលត្រូវបានបង្កើតឡើងនៅក្នុងក្រមនៃ Hammurabi។

**1300s-1400s៖** គណនីដែលទទួលបានមានរូបរាងក្នុងប្រទេសអង់គ្លេសហើយក្លាយជាផ្លូវជំនួញដ៏ពេញនិយមក្នុងឧស្សាហកម្មសម្លៀកបំពាក់។ សម្លៀកបំពាក់ដែលមកដល់ប្រទេសអង់គ្លេសជារឿយៗធ្វើដំណើរឆ្ងាយៗហើយអ្នកដឹកជញ្ជូននឹងត្រូវរង់ចាំទទួលប្រាក់បន្ទាប់ពីការដឹកជញ្ជូនត្រូវបានធ្វើឡើង។ ជាមួយនឹងការណែនាំអំពីហិរញ្ញប្បទាននៃគណនីទទួល អ្នកដឹកជញ្ជូនអាចទទួលបានប្រាក់បៀវត្សរ៍មួយផ្នែកភ្លាមៗ ដែលគ្របដណ្តប់លើការចំណាយលើឧបករណ៍ និងការផ្គត់ផ្គង់។

**1600s៖** អាណានិគមនៃ "ពិភពលោកថ្មី" បានប្រើគណនីដែលទទួលបាន ដើម្បីបង្កើតជីវភាពរស់នៅពីវត្ថុធាតុដើមដែលអាចរកបានដែលពួកគេបានរកឃើញ។ អាណានិគមនឹងដឹកជញ្ជូនថ្នាំជក់រោម កប្បាស និងឈើត្រឡប់ទៅប្រទេសអង់គ្លេសវិញ។ អាណានិគមនឹងផ្តល់ប្រាក់បុរេប្រទានដោយផ្អែកទៅលើភាពរឹងមាំនៃគណនីទទួលរបស់អតិថិជន។

**1800s៖** សូមអរគុណដល់បដិវត្តន៍ឧស្សាហកម្មការផ្តល់ហិរញ្ញប្បទានពីគណនីទទួលបានកាន់តែពេញនិយម។ អ្នកពង្រីកឥណទានបានចាប់ផ្តើមសម្លឹងមើល "ភាពសក្តិសមនៃឥណទាន" របស់អតិថិជន។

**ដើមទសវត្សរ៍ឆ្នាំ 1900៖** ឧស្សាហកម្មដូចជាវាយនភណ្ឌ កាត់ដេរ និងដឹកជញ្ជូនបានចាប់ផ្តើមប្រើប្រាស់គណនីដែលទទួលជាប្រភពសំខាន់នៃហិរញ្ញប្បទានរបស់ពួកគេ។ ពួកគេបានចាប់ផ្តើមប្រើប្រាស់កត្តាជាមធ្យោបាយដើម្បីបន្តទិញវត្ថុធាតុដើមរបស់ពួកគេ។ ការផ្តល់ហិរញ្ញប្បទានពីគណនីបានអនុញ្ញាតឱ្យពួកគេដោះស្រាយជាមួយនឹងវដ្តនៃការលក់ដ៏វែង នៅពេលដែលការដឹកជញ្ជូន និងការចែកចាយទំនិញមិនទាន់អាចទុកចិត្តបាន។

**ឆ្នាំ 1940៖** ធនាគារមួយចំនួនរបស់សហរដ្ឋអាមេរិកចាប់ផ្តើមផ្តល់ជម្រើសកត្តាដែលអាចទទួលបានពីគណនី ផ្ទុយពីអាជីវកម្មទៅនឹងគំរូអាជីវកម្ម។ Factoring ឈានដល់បរិមាណ 2.5 ពាន់លានដុល្លារក្នុងឆ្នាំ 1948។

**ឆ្នាំ 1970-1980៖** ចាប់តាំងពីធនាគារបានចូលរួមក្នុងអាជីវកម្មកត្តា អត្រាការប្រាក់ចាប់ផ្តើមឡើងខ្ពស់ខ្លាំង ហើយបទប្បញ្ញត្តិត្រូវបានរឹតបន្តឹង។ ជាលទ្ធផល គណនីឯកជនក្រុមហ៊ុនកត្តាទទួលប្រាក់ចាប់ផ្តើមកើនឡើង[7]។

[7] *https://www.bing.com/search? e*

**២.១.៣ ទ្រឹស្តីទាក់ទងឥណទេយ្យ**

ការសិក្សានេះបង្ហាញពីប្រវត្តិស៊ីជម្រៅនៃគណនីដែលទទួលពីសម័យបុរាណរហូតដល់សម័យទំនើប។ ជនជាតិបាប៊ីឡូន ក្រិក និងរ៉ូមទាំងអស់បានបង្កើតប្រព័ន្ធសម្រាប់កត់ត្រា និងគ្រប់គ្រងបំណុលដែលជំពាក់ពួកគេ។ ការសិក្សានេះផ្តោតលើការអភិវឌ្ឍន៍នៃ AD នៅសតវត្សរ៍ទី 1 នៃការរក្សាគណនីពីរជង ដែលអាចឱ្យសហគ្រាសរក្សាគណនីរបស់ពួកគេបានកាន់តែត្រឹមត្រូវ និងមានប្រសិទ្ធភាព។ ការសិក្សាប្រើវិធីសាស្ត្រស្រាវជ្រាវពិពណ៌នា។ ការសិក្សានេះ ក៏ស្វែងយល់ពីរបៀបដែលបច្ចេកវិទ្យាបានផ្លាស់ប្តូរវិធីដែលអាជីវកម្មគ្រប់គ្រងគណនីដែលទទួលបានក្នុងសម័យទំនើបនេះ ជាមួយនឹងវិធីសាស្រ្តទូទាត់អេឡិចត្រូនិក និងកម្មវិធីដែលធ្វើឱ្យវាកាន់តែងាយស្រួលសម្រាប់ក្រុមហ៊ុនក្នុងការតាមដាន និងប្រមូលការទូទាត់ពីអតិថិជន។ សរុបសេចក្តីមក កាសែតបានសង្កត់ធ្ងន់ថា អាជីវកម្មអាចគ្រប់គ្រងហិរញ្ញវត្ថុរបស់ពួកគេបានប្រសើរជាងមុន និងពង្រឹងផ្នែកខាងក្រោមរបស់ពួកគេដោយសិក្សាពីប្រវត្តិ និងការវិវត្តនៃគណនីដែលត្រូវទទួល ដើម្បីរក្សាការប្រកួតប្រជែងនៅក្នុងពិភពជំនួញដែលមានល្បឿនលឿននាពេលបច្ចុប្បន្ននេះ ក្រុមហ៊ុនត្រូវតែបន្តសម្របខ្លួន និងទទួលយកបច្ចេកវិទ្យាថ្មីៗ។

**គណនីឥណទេយ្យ** គឺជាពាក្យគណនេយ្យដែលសំដៅលើប្រាក់ជំពាក់ក្រុមហ៊ុនដោយអតិថិជនរបស់ខ្លួន។ វាគឺជាផ្នែកមួយដ៏សំខាន់នៃរបាយការណ៍អំពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនចាប់តាំងពីវាបង្ហាញពីចំនួនប្រាក់ដែលត្រូវបានព្យាករណ៍ថានឹងទទួលបានពីអតិថិជននាពេលអនាគត។ ប្រវត្តិនៃគណនីដែលត្រូវទទួលនៅក្នុងរបាយការណ៍នៃស្ថានភាពហិរញ្ញវត្ថុលាតសន្ធឹងត្រលប់ទៅសម័យដំបូងនៃគណនេយ្យ នៅពេលដែលក្រុមហ៊ុនបានចាប់ផ្តើមតាមដានប្រតិបត្តិការហិរញ្ញវត្ថុរបស់ពួកគេ (Needles & Powers 2013)។ គណនីដែលទទួលនៅក្នុងសេចក្តីថ្លែងការណ៍នៃស្ថានភាពហិរញ្ញវត្ថុមានប្រវត្តិដ៏យូរលង់តាំងពីដើមដំបូងនៃគណនេយ្យ និងវិវត្តន៍តាមពេលវេលាដើម្បីក្លាយជាធាតុផ្សំសំខាន់នៃដំណើរការគណនេយ្យទំនើប (Warren et al. 2013)។

**គណនីឥណទេយ្យ** អាចត្រូវបានតាមដានត្រឡប់ទៅអរិយធម៌អេហ្ស៊ីបបុរាណ និងមេសូប៉ូតាមី ដែលឈ្មួញបានរក្សាទុកកំណត់ត្រានៃប្រតិបត្តិការរបស់ពួកគេនៅលើបន្ទះដីឥដ្ឋ។ បច្ចេកទេសគណនេយ្យពីរជងត្រូវបានបង្កើតឡើងនៅអឺរ៉ុបមជ្ឈិមសម័យ ដែលអនុញ្ញាតឱ្យក្រុមហ៊ុនអាចតាមដានគណនីរបស់ពួកគេកាន់តែមានប្រសិទ្ធភាព។ ការកត់ត្រាចូលពីរជងត្រូវបានបង្កើតឡើងនៅសតវត្សទី1នៃគ.ស ហើយត្រូវបានចាត់ទុកថាជាមូលដ្ឋានគ្រឹះនៃ គណនេយ្យទំនើប (Kiso et al. 2019)។ ប្រព័ន្ធនេះពាក់ព័ន្ធនឹងការកត់ត្រារាល់ប្រតិបត្តិការនៅក្នុងគណនីពីរផ្សេងគ្នា ដោយធានាថាគណនីមានតុល្យភាព។ អាជីវកម្មអាចតាមដានហិរញ្ញវត្ថុរបស់ពួកគេបានកាន់តែត្រឹមត្រូវ និងមានប្រសិទ្ធភាពជាលទ្ធផលនៃបញ្ហានេះ។ ការកត់ត្រាចូលពីរជងក៏បានធ្វើឱ្យកាន់តែងាយស្រួលក្នុងការស្វែងរកកំហុស និងការក្លែងបន្លំ។ កំឡុងសម័យក្រុមហ៊ុន Renaissance Luca Piccioli បានបោះពុម្ពសៀវភៅមួយក្បាលលើប្រធានបទនៅឆ្នាំ1494។ សៀវភៅនេះបានក្លាយជាឯកសារយោងស្តង់ដាសម្រាប់ការកត់ត្រាចូលពីរជង ហើយនៅតែប្រើប្រាស់សព្វថ្ងៃ (Kieso, Weygandt, & Warfield, 2019)។ ការអភិវឌ្ឍន៍នៃការកត់ត្រាចូលពីរជងបានផ្លាស់ប្តូរដំណើរការគណនេយ្យ ហើយមានឥទ្ធិពលយូរអង្វែងលើរបៀបដែលស្ថាប័នគ្រប់គ្រងហិរញ្ញវត្ថុរបស់ពួកគេ។

រាល់ប្រតិបត្តិការនៅក្នុងប្រព័ន្ធនេះត្រូវបានកត់ត្រាក្នុងគណនីពីរផ្សេងគ្នា មួយសម្រាប់ឥណពន្ធ និងមួយទៀតសម្រាប់ឥណទាន។ វិធីសាស្ត្រនេះនៅតែត្រូវបានប្រើប្រាស់សព្វថ្ងៃនេះ និងបម្រើជាមូលដ្ឋានគ្រឹះសម្រាប់ការអនុវត្តគណនេយ្យទំនើប។ ក្នុងអំឡុងបដិវត្តន៍ឧស្សាហកម្មនៃសតវត្សទី18 និងទី19 ការប្រើប្រាស់

គណនីទទួលនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុបានក្លាយជារឿងសាមញ្ញ។ នៅពេលដែលក្រុមហ៊ុនរីកចម្រើន និងពង្រីក ពួកគេទាមទារប្រព័ន្ធស្មុគស្មាញជាងមុនសម្រាប់ការតាមដានសកម្មភាពហិរញ្ញវត្ថុ។ សេចក្តីថ្លែងការណ៍នៃទីតាំងហិរញ្ញវត្ថុបានវិវត្តទៅជាឧបករណ៍សំខាន់មួយសម្រាប់ក្រុមហ៊ុននានាក្នុងការត្រួតពិនិត្យសុខភាពហិរញ្ញវត្ថុរបស់ពួកគេ និងធ្វើការសម្រេចចិត្តវិនិយោគនាពេលអនាគត (Weygandt et al. 2015)។

**គណនីឥណទេយ្យ** គឺជាធាតុផ្សំដ៏សំខាន់នៃរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ហើយពួកវាត្រូវបានប្រើដើម្បីកំណត់ដើមទុនធ្វើការដែលជាចំនួនប្រាក់ដែលអាចចូលប្រើបានសម្រាប់អង្គការសម្រាប់ប្រតិបត្តិការប្រចាំថ្ងៃ។ គណនីដែលត្រូវទទួលក៏អាចត្រូវបានប្រើដើម្បីវាយតម្លៃសាច់ប្រាក់ងាយស្រួលរបស់ក្រុមហ៊ុន ឬសមត្ថភាពរបស់ខ្លួនក្នុងការបំពេញកាតព្វកិច្ចហិរញ្ញវត្ថុរបស់ខ្លួនក្នុងរយៈពេលខ្លី។ ការដាក់បញ្ចូលគណនីដែលត្រូវទទួលនៅលើរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុបានអនុញ្ញាតឱ្យក្រុមហ៊ុនត្រួតពិនិត្យសុខភាពហិរញ្ញវត្ថុរបស់ពួកគេ និងធ្វើការសម្រេចចិត្តប្រកបដោយការអប់រំទាក់ទងនឹងការវិនិយោគនាពេលអនាគត។ ការសិក្សានេះនឹងពិនិត្យមើលការវិវឌ្ឍន៍នៃគណនីដែលត្រូវទទួលនៅលើរបាយការណ៍នៃស្ថានភាពហិរញ្ញវត្ថុពីសម័យបុរាណរហូតមកដល់បច្ចុប្បន្ន ដោយបង្ហាញពីការរីកចម្រើន និងការផ្លាស់ប្តូរសំខាន់ៗដែលជះឥទ្ធិពលដល់នីតិវិធីគណនេយ្យទំនើប។

**គណនីឥណទេយ្យ** គឺជាមូលនិធិដែលអតិថិជនជំពាក់ដល់ក្រុមហ៊ុនសម្រាប់ទំនិញ ឬសេវាកម្មដែលបានទិញដោយឥណទាន។ អ្នកនិពន្ធមួយចំនួនបានកំណត់គណនីទទួលតាមវិធីផ្សេងៗគ្នា៖ គណនីទទួលត្រូវបានកំណត់ដោយ Weygandt et al។ (2015) ជាចំនួនសរុបនៃប្រាក់ជំពាក់ក្រុមហ៊ុនដោយអតិថិជនរបស់ខ្លួនសម្រាប់ទំនិញ ឬសេវាកម្មដែលបានលក់នៅលើឥណទាន ហើយត្រូវបានកត់ត្រាជាទ្រព្យសកម្មបច្ចុប្បន្ននៅលើរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។ និយមន័យនេះសង្កត់ធ្ងន់លើការពិតដែលថាគណនីទទួលគឺជារូបិយប័ណ្ណ។ ការដាក់បញ្ចូលគណនីដែលត្រូវទទួលនៅលើរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុបានអនុញ្ញាតឱ្យក្រុមហ៊ុនត្រួតពិនិត្យសុខភាពហិរញ្ញវត្ថុរបស់ពួកគេ និងធ្វើការសម្រេចចិត្តប្រកបដោយការអប់រំទាក់ទងនឹងការវិនិយោគនាពេលអនាគត។ ការសិក្សានេះនឹងពិនិត្យមើលការវិវឌ្ឍន៍នៃគណនីដែលត្រូវទទួលនៅលើរបាយការណ៍នៃស្ថានភាពហិរញ្ញវត្ថុពីសម័យបុរាណរហូតមកដល់បច្ចុប្បន្ន ដោយបង្ហាញពីការរីកចម្រើន និងការផ្លាស់ប្តូរសំខាន់ៗដែលជះឥទ្ធិពលដល់នីតិវិធីគណនេយ្យទំនើប។

**គណនីឥណទេយ្យ** គឺជាមូលនិធិដែលអតិថិជនជំពាក់ដល់ក្រុមហ៊ុនសម្រាប់ទំនិញឬ សេវាកម្មដែលបានទិញដោយឥណទាន។ អ្នកនិពន្ធមួយចំនួនបានកំណត់គណនីទទួលតាមវិធីផ្សេងៗគ្នា៖ គណនីទទួលត្រូវបានកំណត់ដោយ Weygandt et al។ (2015) ជាចំនួនសរុបនៃប្រាក់ជំពាក់ក្រុមហ៊ុនដោយអតិថិជនរបស់ខ្លួនសម្រាប់ទំនិញ ឬសេវាកម្មដែលបានបម្រើ ឬលក់នៅលើឥណទាន ហើយត្រូវបានកត់ត្រាជាទ្រព្យសកម្មបច្ចុប្បន្ននៅលើរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។ និយមន័យនេះសង្កត់ធ្ងន់លើការពិតដែលថាគណនីទទួលគឺជាទ្រព្យសកម្មបច្ចុប្បន្នដែលតំណាងឱ្យចំនួនប្រាក់ ដែលរំពឹងថានឹងទទួលបានក្នុងរយៈពេលមួយឆ្នាំ។ ក្រុមប្រឹក្សាស្តង់ដាគណនេយ្យហិរញ្ញវត្ថុ (FASB) ផ្តល់និយមន័យមួយផ្សេងទៀតនៃគណនីទទួល។ គណនីដែលត្រូវទទួលត្រូវបានកំណត់ដោយ FASB ជាចំនួនសុទ្ធនៃបំណុលដែលកើតចេញពីការលក់ទំនិញ ឬសេវាកម្មក្នុងដំណើរការធម្មតានៃអាជីវកម្ម (FASB, 2014)។ គណនីដែលត្រូវទទួល យោងទៅតាម Needles and Powers (2013) គឺជាចំនួនលុយដែលជំពាក់អាជីវកម្មដោយអតិថិជនរបស់ខ្លួនសម្រាប់ទំនិញ ឬសេវាកម្ម

ដែលបានលក់នៅលើឥណទាន ហើយវាត្រូវបានចាត់ទុកថាជាទ្រព្យសកម្មមួយនៅលើរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។និយមន័យនេះសង្កត់ធ្ងន់លើសារៈសំខាន់នៃគណនីដែលទទួលជាទ្រព្យសកម្មដែលឆ្លុះបញ្ចាំងពីតម្លៃនៃវិក្កយបត្រដែលមិនទាន់ចេញរបស់ក្រុមហ៊ុន។ គណនីទទួល គឺជាមូលនិធិដែលក្រុមហ៊ុនមានសិទ្ធិទទួលបានពីអតិថិជនរបស់ខ្លួនសម្រាប់ទំនិញ ឬសេវាកម្មដែលលក់ដោយឥណទាន។ យោងតាម Investopedia "គណនីដែលទទួលបានតំណាងឱ្យប្រាក់ជំពាក់ក្រុមហ៊ុនដោយអង្គភាពលើការលក់ផលិតផលឬសេវាកម្មនៅលើឥណទាន" (Investopedia, nd) ។

**គណនីត្រូវទទួល** នេះបើយោងតាមលោក Warren et al។ (2013) គឺជាចំនួនទឹកប្រាក់ដែលអតិថិជនជំពាក់ដល់ក្រុមហ៊ុនសម្រាប់ទំនិញ ឬសេវាកម្មដែលបានលក់នៅលើឥណទាន ហើយត្រូវបានចាត់ទុកថាជាទ្រព្យសកម្មបច្ចុប្បន្ននៅលើរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។ និយមន័យនេះ គឺស្រដៀងគ្នាទៅនឹងនិយមន័យពីមុនហើយសង្កត់ធ្ងន់លើសារៈសំខាន់នៃគណនីទទួលជាទ្រព្យសកម្មបច្ចុប្បន្នដែលឆ្លុះបញ្ចាំងពីតម្លៃនៃវិក្កយបត្រដែលមិនទាន់ចេញរបស់ក្រុមហ៊ុន។ គណនីដែលត្រូវទទួល គឺជាមូលនិធិដែលជំពាក់ក្រុមហ៊ុនដោយអតិថិជនរបស់ខ្លួនសម្រាប់ទំនិញ ឬសេវាកម្មដែលបានលក់នៅលើឥណទាន ហើយពួកគេត្រូវបានកត់ត្រាជាទ្រព្យសកម្មនៅលើរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។ អ្នកនិពន្ធគណនេយ្យជាច្រើន រួមទាំង Needles and Powers (2013), Warren et al. (2013) និង Weygandt et al ។ (2015) គាំទ្រនិយមន័យនេះ[8]។

## ២.២ សារៈសំខាន់ក្នុងការគ្រប់គ្រងគណនេយ្យរបស់ក្រុមហ៊ុន

### ២.២.១ និយមន័យ

**ការគ្រប់គ្រង** គឺជាដំណើរការនៃការប្រើប្រាស់ធនធាន នៅក្នុងអង្គភាពឱ្យទទួលបានជោគជ័យដល់អង្គភាព ដោយមានការរៀបចំ ការធ្វើផែនការ ការដឹកនាំ និងការត្រួតពិនិត្យ[9]។

**ការគ្រប់គ្រង** គឺជាដំណើរការនៃការធ្វើការជាមួយនឹងមនុស្សនិង ធនធានដ៏ទៃទៀតដើម្បីសម្រេចបាននូវគោលដៅរបស់អង្គភាព។ អ្នកដែលគ្រប់គ្រងខ្លាំងពូកែត្រូវមានសមត្ថភាព និងប្រសិទ្ធភាព[10]។

**ការគ្រប់គ្រង** គឺជាដំណើរការរៀបចំចាត់ចែងដឹកនាំនិងត្រួតពិនិត្យដោយប្រើធនធានផ្សេងៗទៀតដើម្បីសម្រេចគោលដៅ[11]។

**ការគ្រប់គ្រង** គឺជាការគ្រប់គ្រង របស់អង្គការមិនថាជា អាជីវកម្ម អង្គការ មិនរកប្រាក់ចំណេញ ឬស្ថាប័នរដ្ឋាភិបាល តាមរយៈការគ្រប់គ្រងអាជីវកម្មការគ្រប់គ្រងមិនស្វែងរកប្រាក់ចំណេញ ឬផ្នែករងវិទ្យាសាស្ត្រនយោបាយនៃរដ្ឋបាលសាធារណៈរៀងៗខ្លួន[12]។

[8] chttps://www.rsisinternational.org
[9] តើការគ្រប់គ្រងមានន័យដូចម្តេច ? (khsearch.com)
[10] https://clubniset.wordpress.com
[11] https://www.khsearch.com
[12] https://en.m.wikipedia.org

២.២.២ មុខងារនៃការគ្រប់គ្រង

មុខងារនៃការគ្រប់គ្រងមាន៤ គឺ ៖

**១.ការធ្វើផែនការ** គឺជាការកំណត់នូវគោលបំណងអង្គភាពបង្កើតយុទ្ធសាស្ត្រអភិវឌ្ឍឋាននុក្រមផែនការ និងធ្វើការសម្របសម្រួលសកម្មភាពទាំងឡាយ។

**២. ការចាត់តាំង** គឺជាការទទួលខុសត្រូវចំពោះគម្រោងរចនាសម្ព័ន្ធរបស់អង្គភាពបែងចែកការងារតម្រូវទៅតាមសមត្ថភាពបុគ្គលដែរត្រូវធ្វើ។

**៣. ការដឹកនាំ** គឺជាការដឹកនាំដោយផ្ទាល់និងសម្របសម្រួលជាមួយក្រុមមនុស្សទាំងអស់ ចេះលើកទឹកចិត្តបុគ្គលិក ដឹកនាំសកម្មភាពអ្នកដទៃ ជ្រើសរើសរបៀបនៃការប្រស្រ័យទាក់ទងដែលមានប្រសិទ្ធភាពបំផុត និងដោះស្រាយជំលោះនៅក្នុងក្រុមការងារ ។

**៤. ការត្រួតពិនិត្យ** គឺដើម្បីធានាថាកិច្ចការទាំងអស់ត្រូវទៅតាមផែនការ ដែលបានគ្រោងទុកប្រៀបធៀបប្រតិបត្តិការជាក់ស្តែងទៅនឹងគោលបំណងអង្គភាព ហើយត្រូវធ្វើការកែប្រែលើចំណុចដែលចាំបាច់[13]។

២.២.៣ ទ្រឹស្តីនៃសារៈសំខាន់ក្នុងការគ្រប់គ្រងឥណទេយ្យ

ទាំងនេះមួយចំនួនត្រូវបានបង្កើតឡើងជាច្រើនសតវត្សមុនក៏ដោយ ក៏ពួកគេនៅតែផ្តល់នូវក្របខ័ណ្ឌស្ថេរភាពសម្រាប់ការដំណើរការអាជីវកម្ម។

**១.ទ្រឹស្តីគ្រប់គ្រងវិទ្យាសាស្ត្រ**

វិស្វករមេកានិកជនជាតិអាមេរិក Frederick Taylor ដែលជាអ្នកទ្រឹស្តីគ្រប់គ្រងដំបូងគេបំផុត បានត្រួសត្រាយទ្រឹស្តីការគ្រប់គ្រងបែបវិទ្យាសាស្ត្រ។ គាត់និងសហការីរបស់គាត់ស្ថិតក្នុងចំណោមបុគ្គលដំបូងគេដែលសិក្សាការងារតាមបែបវិទ្យាសាស្ត្រ។ ទស្សនវិជ្ជារបស់ Taylor បានសង្កត់ធ្ងន់លើការពិតដែលថាការបង្ខំមនុស្សឱ្យធ្វើការនឿយហត់ មិនមែនជាវិធីល្អបំផុតក្នុងការបង្កើនប្រសិទ្ធភាពលទ្ធផលនោះទេ។ ផ្ទុយទៅវិញ Taylor បានផ្តល់អនុសាសន៍ឱ្យធ្វើកិច្ចការសាមញ្ញដើម្បីបង្កើនផលិតភាព។ យុទ្ធសាស្ត្រគឺខុសគ្នាបន្តិចពីរបៀបដែលអាជីវកម្មត្រូវបានធ្វើឡើងពីមុន។ ដំបូងឡើយ នាយកប្រតិបត្តិរោងចក្រវីការាយនឹងទំនាក់ទំនងតិចតួចបំផុតជាមួយនិយោជិតរបស់គាត់។ វាគ្មានវិធីណាក្នុងការកំណត់ស្តង់ដានៃច្បាប់នៅកន្លែងធ្វើការនោះទេ ហើយការលើកទឹកចិត្តតែមួយគត់របស់និយោជិតគឺសុវត្ថិភាពការងារ។ យោងតាម Taylor ប្រាក់គឺជាការលើកទឹកចិត្តដ៏សំខាន់សម្រាប់ការងារ ដែលនេះជាមូលហេតុដែលគាត់បង្កើតគំនិត "ប្រាក់ឈ្នួលថ្ងៃសមរម្យសម្រាប់ការងារប្រចាំថ្ងៃ"។ ចាប់តាំងពីពេលនោះមក ទ្រឹស្តីគ្រប់គ្រងបែបវិទ្យាសាស្ត្រត្រូវបានអនុវត្តន៍នៅទូទាំងពិភពលោក។ ការសហការគ្នាជាលទ្ធផលរវាងនិយោជិត និងនិយោជកបានវិវត្តទៅជាការងារជាក្រុមដែលមនុស្សចូលចិត្តឥឡូវនេះ[14]។

**២.ទ្រឹស្តីការគ្រប់គ្រងប្រព័ន្ធ**

ការគ្រប់គ្រងប្រព័ន្ធផ្តល់នូវវិធីសាស្ត្រជំនួសសម្រាប់ការធ្វើផែនការ និងការគ្រប់គ្រងអង្គការ។ ទ្រឹស្តីគ្រប់គ្រងប្រព័ន្ធស្នើរថាអាជីវកម្ម ដូចជារាងកាយមនុស្សមានធាតុផ្សំជាច្រើនដែលធ្វើការចុះសម្រុងគ្នា ដើម្បីឱ្យប្រព័ន្ធធំអាចដំណើរការបានល្អបំផុត។ យោងតាមទ្រឹស្តី ភាពជោគជ័យនៃអង្គការមួយអាស្រ័យទៅលើធាតុសំខាន់ៗមួយចំនួន៖ ភាពស៊ីសង្វាក់គ្នា ការពឹងពាក់គ្នាទៅវិញទៅមក និងទំនាក់ទំនងរវាងប្រព័ន្ធរងផ្សេងៗ។

[13] https://www.khsearch.com
[14] https://corporatefinanceinstitute.com

បុគ្គលិកគឺជាធាតុផ្សំដ៏សំខាន់បំផុតមួយរបស់ក្រុមហ៊ុន។ ជាតុផ្សេងទៀតដែលមានសារៈសំខាន់ចំពោះភាពជោគជ័យនៃអាជីវកម្មគឺនាយកដ្ឋាន ក្រុមការងារ និងអង្គភាពអាជីវកម្ម។ នៅក្នុងការអនុវត្ត អ្នកគ្រប់គ្រងត្រូវបានតម្រូវឱ្យវាយតម្លៃគំរូ និងព្រឹត្តិការណ៍នៅក្នុងក្រុមហ៊ុនរបស់ពួកគេ ដើម្បីកំណត់វិធីសាស្ត្រគ្រប់គ្រងដ៏ល្អបំផុត។ វិធីនេះ ពួកគេអាចសហការគ្នាលើកម្មវិធីផ្សេងៗ ដើម្បីឱ្យពួកគេអាចធ្វើការជាសមូហភាពជាជាងជាឯកតាដាច់ដោយឡែក[15]។

### ៣. ទ្រឹស្តីការគ្រប់គ្រងភាពអាសន្ន

